**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៦ - អនក្រ - បក

# អនុក្រឹត្យ

## ស្តីពី

## ការគ្រប់គ្រងនិងការចាត់ចែងថវិការបស់ស្ថាប័នប្រឆាំងអំពើពុករលួយ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១០/០០៤ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ស្តីពីបៀវត្សរ៍មូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរ៍របស់មន្ត្រីរាជការស៊ីវិល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់អំពីការគ្រប់គ្រងនិងការចាត់ចែងថវិកា របស់ស្ថាប័នប្រឆាំងអំពើពុករលួយ។

## ជំពូកទី២
## ការគ្រប់គ្រងនិងការចាត់ចែងថវិកា

**មាត្រា ២.-**

ស្ថាប័នប្រឆាំងអំពើពុករលួយ មានកញ្ចប់ថវិកាដោយឡែក សម្រាប់ដំណើរការសកម្មភាពការងាររបស់ខ្លួន។

**មាត្រា ៣.-**

កញ្ចប់ថវិកាដោយឡែកសម្រាប់ដំណើរការ របស់អង្គភាពប្រឆាំងអំពើពុករលួយ មានបរិមាណស្មើនឹង ០,២% ទៅ ០,៣% នៃចំណាយចរន្តសរុបរបស់ថវិកាថ្នាក់ជាតិ។ អត្រានេះត្រូវបានពិនិត្យឡើងវិញនៅរៀងរាល់ ៣ឆ្នាំម្តង។ ក្នុងករណីពិសេស អង្គភាពប្រឆាំងអំពើពុករលួយ អាចស្នើសុំរាជរដ្ឋាភិបាលនូវថវិកាបន្ថែមតាមការចាំបាច់។

**មាត្រា ៤.-**

អង្គភាពប្រឆាំងអំពើពុករលួយ ពិនិត្យ និងលើកគម្រោងថវិកាប្រចាំឆ្នាំ របស់ស្ថាប័នប្រឆាំងអំពើពុករលួយដាក់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ឯកសារចំណាយសម្រាប់បេសកកម្មពិសេស ចារកម្ម និងស៊ើបអង្កេតសម្ងាត់ របស់អង្គភាពប្រឆាំងអំពើពុករលួយ មិនអាចត្រូវបានលាតត្រដាងបានឡើយ។

**មាត្រា ៥.-**

ថ្នាក់ដឹកនាំនិងមន្ត្រីរាជការនៃក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ និងអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវទទួលប្រាក់បំណាច់ប្រឆាំងអំពើពុករលួយហៅថា ប្រាក់បំណាច់មុខងារដោយឡែក បន្ថែមលើប្រាក់បៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិលប្រចាំខែ។

តាមសំណើរបស់ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុទទួលបន្ទុករៀបចំប្រាក់បំណាច់ប្រឆាំងអំពើពុករលួយ និងលើកសំណើជូននាយករដ្ឋមន្ត្រីដើម្បីពិនិត្យសម្រេច។

**មាត្រា ៦.-**

ថ្នាក់ដឹកនាំនិងមន្ត្រីរាជការ ដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ ដែលកាន់មុខតំណែងច្រើន មានសិទ្ធិទទួលប្រាក់បំណាច់ប្រឆាំងអំពើពុករលួយបានតែមួយមុខតំណែង ក្នុងមុខតំណែងណាមួយក៏បាន។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ប្រធានអង្គភាពប្រឆាំងអំពើពុករលួយ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០១១

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ